# GC LiFE



# "Life Shield" Insurance

# "គម្រោងការពារខ្លួន"

> រយៈពេលធានារ៉ាប់រងមានរយៈពេល១ឆ្នាំ។ ក្រោយដល់កាលកំណត់លោកអ្នកអាចធ្វើការស្នើសុំបន្តធានារ៉ាប់រងបាន។

## បុព្វលាភធានារ៉ាប់រង និងអតិបរមានៃសំណងធានារ៉ាប់រង

បុព្វលាភធានារ៉ាប់រង និងអតិបរមានៃសំណងធានារ៉ាប់រង សមាមាត្រទៅនឹងតារាងខាងក្រោម ក្នុងនោះបែងចែកជាគម្រោង A, B, និងC ហើយលោកអ្នកអាចធ្វើការជ្រើសរើសគម្រោងណាមួយក្នុងចំណោមនោះ

### តារាងសមាមាត្ររវាងបុព្វលាភធានារ៉ាប់រង និងអតិបរមានៃសំណងធានារ៉ាប់រង

រូបិយបណ្ណ: ដុល្លារសហរដ្ឋអាមេរិក

| គម្រោង | បុព្វលាភធានារ៉ាប់រង | អតិបរមានៃសំណងធានារ៉ាប់រងមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយជំងឺ | អតិបរមានៃសំណងធានារ៉ាប់រងមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ដោយចៃដន្យ |
|---|---|---|---|
| A | 23 | 0/100/500/1000 | 5000 |
| B | 43 | 0/200/1000/2000 | 10000 |
| C | 80 | 0/400/2000/4000 | 20000 |

"អតិបរមានៃសំណងធានារ៉ាប់រងមរណភាពឬពិការភាពជាអចិន្ត្រៃយ៍ដោយជំងឺ" នៅក្នុងតារាងខាងលើត្រូវបានអនុវត្តន៍តាមរយៈពេលមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងនិងគម្រោង។ មុនពេលដែលកិច្ចសន្យាធានារ៉ាប់រងមានអនុភាពមិនទាន់គ្រប់រយៈពេល ២ខែ ចំពោះសំណងធានារ៉ាប់រងសម្រាប់គម្រោង A , B , C គឺមានចំនួន០ដុល្លារសហរដ្ឋអាមេរិក។ ក្រោយរយៈពេល ២ខែ ចំពោះសំណងធានារ៉ាប់រងសម្រាប់គម្រោង A គឺមានចំនួន ១០០ដុល្លារសហរដ្ឋអាមេរិក សម្រាប់គម្រោង B គឺមានចំនួន ២០០ដុល្លារសហរដ្ឋអាមេរិក ហើយសម្រាប់គម្រោង C គឺមានចំនួន ៤០០ដុល្លារសហរដ្ឋអាមេរិក។ ក្រោយរយៈពេល ៤ខែ ចំពោះសំណងធានារ៉ាប់រងសម្រាប់គម្រោង A គឺមានចំនួន ៥០០ដុល្លារសហរដ្ឋអាមេរិក សម្រាប់គម្រោង B គឺមានចំនួន ១.០០០ដុល្លារសហរដ្ឋអាមេរិក ហើយសម្រាប់គម្រោង C គឺមានចំនួន ២.០០០ដុល្លារសហរដ្ឋអាមេរិក។ ក្រោយរយៈពេល ៦ខែ ចំពោះសំណងធានារ៉ាប់រងសម្រាប់គម្រោង A គឺមានចំនួន ១.០០០ដុល្លារសហរដ្ឋអាមេរិក សម្រាប់គម្រោង B គឺមានចំនួន ២.០០០ដុល្លារសហរដ្ឋអាមេរិក ហើយសម្រាប់គម្រោង C គឺមានចំនួន ៤.០០០ដុល្លារសហរដ្ឋអាមេរិក។

## វិសាលភាពនៃការធានា

១.ក្នុងករណីទទួលមរណភាពឬពិការភាពជាអចិន្ត្រៃយ៍ដោយសារជំងឺ យោងតាមសមាមាត្ររវាងគម្រោងនិងអតិបរមានៃសំណងធានារ៉ាប់រងមរណភាពឬពិការភាពជាអចិន្ត្រៃយ៍ដោយជំងឺ ផ្តល់សំណងធានារ៉ាប់រង ដោយអនុលោមតាមតារាងខាងលើ។

២. ក្នុងករណីទទួលមរណភាពឬពិការភាពជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ យោងតាមសមាមាត្ររវាងគម្រោង និងអតិបរមានៃសំណងធានារ៉ាប់រងមរណភាពឬពិការភាពជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ ផ្តល់សំណងធានារ៉ាប់រង ដោយអនុលោមតាមតារាងខាងលើ។

៣. អត្ថប្រយោជន៍នៅពេលស្នើសុំបន្តធានារ៉ាប់រង

ប្រសិនបើអ្នកស្នើសុំផ្ញើការស្នើសុំបន្តធានារ៉ាប់រង ក្រុមហ៊ុននឹងផ្តល់ជូននូវអត្ថប្រយោជន៍ដូចខាងក្រោម :

(១)អតិបរមានៃសំណងធានារ៉ាប់រងមរណភាពឬពិការភាពជាអចិន្ត្រៃយ៍ដោយជំងឺត្រូវអនុលោមតាម:

ចំពោះគម្រោង A ផ្តល់ជូនទឹកប្រាក់ចំនួន ១.០០០ ដុល្លារសហរដ្ឋអាមេរិក

ចំពោះគម្រោង B ផ្តល់ជូនទឹកប្រាក់ចំនួន ២.០០០ ដុល្លារសហរដ្ឋអាមេរិក

ហើយចំពោះគម្រោង C ផ្តល់ជូនទឹកប្រាក់ចំនួន ៤.០០០ ដុល្លារសហរដ្ឋអាមេរិក។

(២) ចំពោះការស្នើសុំបន្តធានារ៉ាប់រងលើកទី១ អតិបរមានៃសំណងធានារ៉ាប់រងនីមួយៗនឹងត្រូវបង្កើនចំនួន ១០%។

(៣) ចំពោះការស្នើសុំបន្តធានារ៉ាប់រងលើកទី២ អតិបរមានៃសំណងធានារ៉ាប់រងនីមួយៗនឹងត្រូវបង្កើនចំនួន ២០%។

(៤)ចំពោះការស្នើសុំបន្តធានារ៉ាប់រងលើកទី៣ និងលើកក្រោយៗទៀត អតិបរមានៃសំណងធានារ៉ាប់រងនីមួយៗនឹងត្រូវបង្កើនចំនួន ៣០%។

យើងខ្ញុំសូមណែនាំឲ្យលោកអ្នកជាវនូវផលិតផលធានារ៉ាប់រងបន្ថែមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដើម្បីទទួលបាននូវការធានាកាន់តែទូលំទូលាយ។

## ករណីលើកលែង

១.ក្រុមហ៊ុនធានារ៉ាប់រងមិនមានកាតព្វកិច្ចសងសំណងធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពដោយសារតែព្រឹត្តិការណ៍ណាមួយដូចខាងក្រោម ៖

(1)អ្នកត្រូវបានធានារ៉ាប់រងស្នើសុំធានារ៉ាប់រងទាំងខ្លួនមានជំងឺ ហើយនៅពេលដែលអ្នកស្នើសុំធានារ៉ាប់រងបំពេញបែបបទស្នើសុំមិនបានប្រាប់នូវការពិតនៃស្ថានភាពជំងឺនោះ

(2)អ្នកស្នើសុំជានារ៉ាប់រងមានចេតនាធ្វើឃាត ឬបង្ករបួសទៅលើអ្នកត្រូវបានជានារ៉ាប់រង
(3)អ្នកត្រូវបានជានារ៉ាប់រងបានប្រព្រឹត្តបទល្មើស ឬប្រឆាំងនឹងវិធានការបង្ខិតបង្ខំណាមួយតាមផ្លូវច្បាប់
(4)អ្នកត្រូវបានជានារ៉ាប់រងធ្វើអត្តឃាត ឬបង្ករបួសលើខ្លួនឯងដោយចេតនា លើកលែងតែនៅពេលធ្វើអត្តឃាត ឬការបង្ករបួសលើខ្លួនឯងដោយចេតនា អ្នកត្រូវបានជានារ៉ាប់រងបានបាត់បង់សមត្ថភាពផ្នែកស៊ីវិលរបស់ខ្លួនដែលកំណត់ដោយច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា
(5)អ្នកត្រូវបានជានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការវាយតប់គ្នា ឬការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន
(6)អ្នកត្រូវបានជានារ៉ាប់រងបើកបរក្នុងស្ថានភាពស្រវឹង បើកបរក្នុងស្ថានភាពគ្រោះថ្នាក់ បើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ ឬបើកបរយានយន្តដែលគ្មានការចុះបញ្ជីត្រឹមត្រូវដែលបានកំណត់ដោយច្បាប់
(7)អ្នកត្រូវបានជានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការជ្រមុជទឹក ការលោតឆ័ត្រយោង ការឡើងភ្នំ ការផ្សងព្រេង ការសម្តែងបច្ចេកទេសពិសេស ការប្រណាំងរថយន្ត
(8)ការពិនិត្យមុននិងក្រោយមានផ្ទៃពោះ  ការមានផ្ទៃពោះ(រួមមានកូនក្រៅស្បូន) ការរលូតកូន  (រួមទាំងការរំលូតកូន) ការសម្រាលកូន (រួមទាំងការសម្រាលកូនដោយវះកាត់) ការពន្យារកំណើត ការវះកាត់មិនឲ្យមានកូន ការព្យាបាលឲ្យមានកូននិងជំងឺផ្សេងទៀតដែលវិវឌ្ឍន៍ចេញពីជំងឺខាងលើនេះរបស់អ្នកស្នើសុំ ឬអ្នកត្រូវបានជានារ៉ាប់រងដែលបណ្តាលអោយកើតមានគ្រោះថ្នាក់ស្ថិតក្រោមវិសាលភាពនៃការធានាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ
(9)អ្នកត្រូវបានជានារ៉ាប់រងខកខានមិនបានអនុវត្តតាមវេជ្ជបញ្ជាវេជ្ជសាស្ត្រហើយប្រើប្រាស់ ឬលេបថ្នាំដោយខ្លួនឯង (លើកលែងតែការប្រើប្រាស់ថ្នាំតាម វេជ្ជបញ្ជាដោយយោងតាមការណែនាំសម្រាប់ការប្រើប្រាស់)
(10)អ្នកត្រូវបានជានារ៉ាប់រងទទួលរងនូវឧប្បត្តិហេតុខាងវេជ្ជសាស្ត្រ ដោយសារការវះកាត់កែសម្ផស្ស ឬការវះកាត់ផ្សេងៗ
(11)អ្នកត្រូវបានជានារ៉ាប់រងមានជំងឺសតិអារម្មណ៍ ឬអាកប្បកិរិយាមិនប្រក្រតី
(12)សង្គ្រាម ការប៉ះទង្គិចផ្នែកយោធា ការបះបោរ ឬការបះបោរប្រដាប់អាវុធ
(13)ការផ្ទុះនុយក្លេអ៊ែរ វិទ្យុសកម្មនុយក្លេអ៊ែរ ឬការចម្លងរោគពីនុយក្លេអ៊ែរ
(14)អ្នកត្រូវបានជានារ៉ាប់រងជួបគ្រោះថ្នាក់ជាយថាហេតុដែលបណ្តាលឲ្យទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ក្រោយរយៈពេល១៨០ថ្ងៃគិតចាប់ពីថ្ងៃកើតហេតុនោះ

២. រាល់ការចំណាយលើការព្យាបាលជំងឺរបស់អ្នកត្រូវបានជានារ៉ាប់រង ឬការចំណាយសម្រាប់ការពិនិត្យជំងឺ និងការចំណាយសម្រាប់ការសម្រាកនៅមន្ទីរពេទ្យដែលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុដែលមិនស្ថិតក្នុងវិសាលភាពនៃការធានា

របស់កិច្ចសន្យានេះ ក្រុមហ៊ុនធានារ៉ាប់រងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណង
ឡើយ។ ប្រសិនបើមានកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងបន្ថែមភ្ជាប់ជាមួយ
នឹងកិច្ចសន្យានេះ ត្រូវអនុវត្តន៍តាមកិច្ចសន្យារបស់ផលិតផលធានារ៉ាប់រងបន្ថែម។

"The period of insurance is one year and renewal of policy is available after maturity."

## PREMIUM AND SUM INSURED

There are three plans (A, B, C) for the premium and the corresponding sum insured as stated in the table below under this section. Please select one of the three plans.

### Table of Premium and Corresponding Sum Insured

Currency Unit: US dollar

| Plan | Premium | Sum Insured for Death or Total Disability Due to Illness | Sum Insured for Accidental Death or Total Disability Due to Accidental Injury Benefit |
|---|---|---|---|
| A | 23 | 0/100/500/1000 | 5000 |
| B | 43 | 0/200/1000/2000 | 10000 |
| C | 80 | 0/400/2000/4000 | 20000 |

The "Sum Insured for Death or Total Disability Due to Illness" stated in the table above is determined by the effective date of the Contract and the selected Plan: Within the first 2 months from the effective date of the Contract, the sum insured for death or total disability due to illness under Plan A, B, C is zero. After 2 months from the effective date of the Contract, the sum insured for death or total disability due to illness under Plan A is 100 US dollar; under Plan B is 200 US dollar; under Plan C is 400 US dollar. After 4 months from the effective date of the Contract, the sum insured for death or total disability due to illness under Plan A is 500 US dollar; under Plan B is 1,000 US dollar; under Plan C is 2,000 US dollar. After 6 months from the effective date of the Contract, the sum insured for death or total disability due to illness under Plan A is 1,000 US dollar; under Plan B is 2,000 US dollar; under Plan C is 4,000 US dollar.

## COVERAGE

1. For death or total disability due to illness, the sum insured for death or total disability is based on the selected plan stated on the table above.

2. For death or total disability due to an accidental injury the sum insured for the accidental death or the sum insured for total disability due to accidental injury is based on selected plan stated on the table above.

3. Continuous Renewal Benefit

If the applicant renews the policy, the Company will offer the following renewal benefits:

(1) The "Sum Insured for Death or Total Disability Due to Illness" shall be 1,000 US dollar for Plan A; 2,000 US dollar for Plan B; 4,000 US dollar for Plan C;

(2) The first time the Contract is renewed, each sum insured shall be increased by 10%;

(3) The second time the Contract is renewed, each sum insured shall be increased by 20%;

(4) From the third and subsequent times the Contract is renewed, each sum insured shall be increased by 30%.

We recommend you to purchase our "Accidental Injury Hospitalization Allowance Rider" as well in order to maximize your coverage.

## EXCLUSION

1. If the Insured dies due to any of the following events, the Company shall not be obliged to pay the insurance benefit:

(1) The Insured has already been diagnosed with an illness at the time of applying for the insurance and the applicant did not declare such illness during the application process.

(2) The Insured is intentionally murdered or harmed by the applicant;

(3) The Insured commits an offence or resists any legal criminal enforcement measure;

(4) Suicide or deliberate self-injury of the Insured, unless the Insured has lost his/her civil capacity defined by the Kingdom of Cambodia when committing suicide or deliberate self-injury;

(5) The Insured is involved in a fight, or is intoxicated from alcohol, or drugs;

(6) The Insured is speeding, drinking and driving over the legal limit, driving without a valid driver license, or driving a vehicle without a valid registration;

(7) The Insured is involved in diving, skydiving, climbing, adventure, extreme stunt show, car racing;

(8) The Insured undergoes prenatal and postnatal examinations, pregnancy (including ectopic pregnancy), miscarriage (including abortion), delivery (including caesarean), contraception, sterilization surgery, infertility treatment and the complications caused by the aforementioned reasons;

(9) The Insured fails to follow the medical prescription and uses or takes drugs by him or herself (except for the use of non-prescribed medicines according to the direction for use);

(10) The Insured suffers from any medical accident due to plastic surgery or other surgical operation;

(11) The Insured suffers from mental and behavioral disorder;

(12) War, military clash, riot or armed rebellion;

(13) Nuclear explosions, nuclear radiation or nuclear contamination;

(14) The Insured dies or becomes totally disabled due to accidental injury after 180 days of the date of accident.

2. Any expense related to the medical treatment of the Insured or any outpatient and hospitalization fee arisen from accidental injury is not covered under this Contract and the Company shall not be obliged to pay any insurance benefit. If there are riders attached to the Contract, the Company shall execute the other contracts accordingly.